# សេចក្តីជូនដំណឹង
# ស្តីពី
# កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ទទួលជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ (“កិច្ចប្រជុំ”) តាមរយៈ **អ៊ីម៉ែល** ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥** ចាប់ពីម៉ោង **១៣:០០** ដល់ម៉ោង **១៥:០០ រសៀល** (ម៉ោងនៅភ្នំពេញ) តាមរបៀបវារៈ៖

- អនុម័តលើការបង្កើនដើមទុនចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា។

ភាគហ៊ុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក**នៅកាលបរិច្ឆេទកំណត់ទុកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥** នឹងទទួលបានលិខិតអញ្ជើញ ឯកសារគាំទ្រ សេចក្តីណែនាំការបោះឆ្នោតតាមប្រព័ន្ធ e-Voting លិខិតប្រគល់សិទ្ធិ និង QR Code សម្រាប់ការបោះឆ្នោត ដែលធនាគារ អេស៊ីលីដា នឹងផ្ញើជូនតាមរយៈអ៊ីម៉ែល។ ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទកំណត់ទុក អាចផ្តល់សិទ្ធិប្រទានទៅឱ្យអ្នកតំណាងណាម្នាក់ ដើម្បីចូលរួម និងបោះឆ្នោតជំនួសបាន។ ភាគហ៊ុនិក ឬអ្នកទទួលសិទ្ធិត្រូវផ្ញើលិខិតប្រគល់សិទ្ធិច្បាប់ដើមមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា យ៉ាងយូរត្រឹម**ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥**។

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

❖ ធនាគារ អេស៊ីលីដា នឹងផ្ញើ QR Code សម្រាប់ការបោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗ តាមរយៈអ៊ីម៉ែល ចាប់ពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៥ ម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ម៉ោង ១២:០០ ថ្ងៃត្រង់ (ម៉ោងនៅភ្នំពេញ)។

❖ ភាគហ៊ុនិកម្នាក់ៗត្រូវបោះឆ្នោតនៅ**ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥** ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង **១៣:០០** ដល់ម៉ោង **១៥:០០ រសៀល** (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code សម្រាប់ការបោះឆ្នោត (សូមមើលសេចក្តីណែនាំការបោះឆ្នោតតាមប្រព័ន្ធ e-Voting ដែលនឹងផ្ញើជូនជាមួយ QR Code)។

**បញ្ជាក់៖**

- ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនៅ**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥**។
- ភាគហ៊ុនិកដែល **លក់** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ គឺនៅតែមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាត។
- ភាគហ៊ុនិកដែល **ទិញ** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥** គឺ **មិនមានសិទ្ធិ**ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតឡើយ។


អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំនេះ តាមរយៈអ៊ីម៉ែលតាមកាលបរិច្ឆេទដែលបានកំណត់ទុកដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (ភ្នាក់ងារ RTP) របស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

- **លោក ហួត សុភី**
  - ➢ ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - ➢ អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  - ➢ ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  - ➢ អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  - ➢ ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  - ➢ អ៊ីម៉ែល: op.rtp@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  - ➢ ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - ➢ អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃពុធ ១៥រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**